សលាកប័ត្រព័ត៌មាន NEWSLETTER
លេខ: ៤៥ ខែសីហា ឆ្នាំ២០០៩
Issue: 45 August 2009

# ឃ្លាំមើល សាលាក្តីខ្មែរក្រហម
KHMER ROUGE TRIBUNAL (KRT) WATCH

គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា
CAMBODIAN HUMAN RIGHTS ACTION COMMITTEE
ADHOC - CARAM - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP - IDA - KKKHRO - KKKHRDA - KID - KIND - KSA - KYA - LAC - PDP -PJJ - VIGILANCE

## សិក្ខាសាលា ស្តីពី កិច្ចសម្របសម្រួលការងារផ្សព្វផ្សាយ
## Outreach Harmonization Workshop

សិក្ខាសាលា ស្តីពី កិច្ចសម្របសម្រួលការងារផ្សព្វផ្សាយ ត្រូវបាន រៀបចំឡើងដោយគណៈកម្មាធិការប្រព្រឹត្តិកម្ម ដោយរួមសហការគ្នា ជាមួយនឹងអង្គភាពជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០០៩ កន្លងទៅនេះ ដោយមានការចូលរួមពីសំណាក់បុគ្គលិកអង្គភាពជនរងគ្រោះ មន្ត្រីការិយាល័យកិច្ចការសាធារណៈរបស់សាលាក្តី តំណាងអង្គការមិនមែនរដ្ឋាភិបាល និងអ្នកសិក្សាស្រាវជ្រាវ ប្រមាណជាង ៧០នាក់ នៅភ្នំពេញ។




*គណៈអធិបតីពេលបើកសិក្ខាសាលា*

នៅក្នុងពេលបើកសិក្ខាសាលា លោកស្រី **ហេឡែន ចារវីស** ប្រធានអង្គភាពជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានលើកឡើងថា សិក្ខាសាលានៅថ្ងៃនេះ មានសារៈសំខាន់ណាស់ ដើម្បីផ្តល់ឱកាសដល់មន្ត្រី នៃអង្គភាពជនរងគ្រោះ ខាងផ្នែកការងារផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិលនានា ដែលធ្វើការលើវិស័យផ្សព្វផ្សាយព័ត៌មានអំពីដំណើរការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ក៏ដូចជាការជួយគាំទ្រការចូលរួមរបស់ជនរងគ្រោះ ជជែកពិភាក្សាគ្នាលំអិត ក្នុងគោលបំណងស្វែងរកនូវយុទ្ធសាស្ត្ររួមគ្នា ដើម្បីជួយពង្រឹងការងារផ្សព្វផ្សាយនេះឱ្យកាន់តែបានទូលំទូលាយថែមទៀត។ លោកស្រីបានគូសបញ្ជាក់ថា រហូតមកដល់ពេលនេះ មានពាក្យបណ្តឹងជនរងគ្រោះ យ៉ាងហោចណាស់ចំនួន ៤,០៧២ បានទទួលដោយអង្គភាពរបស់ លោកស្រី ហើយក្នុងនោះ ក៏មានពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១,៨៧៦ ផងដែរ។ នៅក្នុងសំណុំរឿង ០០១ បច្ចុប្បន្ន មានដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៤ ហើយ នៅក្នុងសំណុំរឿង ០០២ វិញ មានជនរងគ្រោះចំនួន ១០៣នាក់ ហើយដែលត្រូវបានសហចៅក្រមស៊ើបអង្កេតទទួលស្គាល់ជា ភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលក្នុងនោះ ជនរងគ្រោះភាគច្រើនរស់នៅក្នុងប្រទេសកម្ពុជា ហើយ ៦៤នាក់ ជាជនជាតិខ្មែររស់ នៅបរទេសដូចជា: ប្រទេសបារាំង, សហរដ្ឋអាមេរិក, លុច្សំបួរ, កាណាដា, អូស្ត្រាលី និង ញូហ្សេលែន។ លោកស្រីក៏បានគូសបញ្ជាក់បន្ថែមទៀតថា ការដែលមានជនរងគ្រោះជាច្រើន ចូលរួមនៅក្នុងដំណើរការនីតិវិធីរបស់សាលាក្តីបច្ចុប្បន្ននេះ ពិតជាបានមកដោយមានកិច្ចសហការ និងការជួយជ្រោមជ្រែងពីសំណាក់អង្គការអន្តរការីមួយចំនួន ហើយជាពិសេសនោះ គឺ តំណាងអង្គការអន្តរការី ដែលបានចូលរួមនៅក្នុងសិក្ខាសាលានាពេលនេះ។

ជាលទ្ធផល សិក្ខាសាលានេះបានសម្រេចនូវយុទ្ធសាស្ត្ររួមគ្នា ជាពិសេស ទៅលើកិច្ចសហការរវាងអង្គភាពជនរងគ្រោះ និងអង្គការអន្តរការី ជុំវិញផែនការការងារផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយថែមទៀត ជាពិសេសសំរាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់ និងអ្នកដែលបានដាក់ពាក្យបណ្តឹងរួចហើយ។ ក្នុងនោះដែរ សមាជិក សមាជិកា ក៏បានជជែកពិភាក្សាទៅលើផែនការ កិច្ចសហការ និងកិច្ចសម្របសម្រួលទាក់ទិនការរៀបចំធ្វើវេទិកាតំបន់សំរាប់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី, ការជ្រើសរើសអ្នកទំនាក់ទំនងសំរាប់ក្រុមដើមបណ្តឹងរដ្ឋប្បវេណី,ការបំពេញទំរង់ពាក្យបណ្តឹងដែលនៅមិនទាន់ពេញលេញ និងជំនួបរវាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីតំណាង ដើម្បីឱ្យសិទ្ធិ និងតួនាទីនៃការចូលរួមរបស់ជនរងគ្រោះកាន់តែមានអត្ថន័យ ហើយពេញលេញ ស្របទៅតាមគោលការណ៍ច្បាប់ និងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ។

នៅក្នុងកិច្ចបញ្ចប់សិក្ខាសាលានេះដែរ លោក **សុក សំអឿន** ប្រធានសម្របសម្រួលគណៈកម្មាធិការប្រព្រឹត្តិកម្ម បានសង្កត់ធ្ងន់ថា ការចូលរួមរបស់ជនរងគ្រោះនៅក្នុងដំណើរការស្វែងរកយុត្តិធម៌តាមរយៈសាលាក្តីខ្មែរក្រហមនេះ មានសារៈសំខាន់ណាស់ ដើម្បីធ្វើជាគំរូអនុវត្ត ជាប្រវត្តិសាស្ត្រ និងអាចជួយរំសាយនូវភាពឈឺចាប់ពីអតីតកាល ដែលជនរងគ្រោះបានជួបប្រទះផងដែរ៕

# ឌុច បកស្រាយឧក្រិដ្ឋកម្មនៅមន្ទីរស-២១

## Duch Describes Crimes Committed at S-21 Center

នៅខណៈដែលសំណុំរឿង០០២ ប្រឆាំងនឹងអតីតមេដឹកនាំចំនួន ៤រូប ផ្សេងទៀត កំពុងស្ថិតនៅក្នុងតំណាក់កាលស៊ើបអង្កេតនៅឡើយ ការបើកសវនាការជំនុំជម្រះទៅលើអតីតប្រធានមន្ទីរស-២១ ឈ្មោះ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** នៅតែបន្តធ្វើចាប់តាំងពីចុងខែមីនា ឆ្នាំ២០០៩ នេះ មកម្ល៉េះ។ ការបើកសវនាការជាបន្តបន្ទាប់មកនេះ គឺដោយសារថា ចៅក្រម នៃអង្គជំនុំជម្រះសាលាដំបូង និងភាគីទាំងអស់នៅក្នុងសំណុំរឿងរួមបញ្ចូលទាំង ភាគីសហព្រះរាជអាជ្ញា, សហមេធាវីការពារ **ឌុច** និងក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវការជជែកដេញដោលទៅលើភស្តុតាងនានា ព្រមទាំងសក្ខីកម្មរបស់សាក្សី និងសាក្សីជាអ្នកជំនាញផ្សេងៗ ដែលមានជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋ-កម្ម ដែលបានប្រព្រឹត្តនៅមន្ទីរស-២១ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីចន្លោះថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩ ។



*ឌុច (រូបកណ្តាល ពាក់អាវស) ជាមួយនឹងសហមេធាវីរបស់គាត់*

អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញ ដែល មានចៅក្រមចំនួន ៥រូប ក្នុងនោះ មានចៅក្រមជាតិចំនួន ៣ រូប និង ចៅក្រមអន្តរជាតិចំនួន ២រូប ដឹកនាំដោយ លោក **និល ណុល** បានបើកការជំនុំជម្រះក្តីទៅលើជនជាប់ចោទ **ឌុច** ដែលធ្លាប់ជាប្រធានមន្ទីរស-២១ ឬមន្ទីរសន្តិបាលពិសេសរបស់បក្សកុម្មុយនីស្តកម្ពុជា អំពីឧក្រិដ្ឋកម្មទាំងឡាយ ដែលបានកើតឡើងនៅក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ជនជាប់ចោទរូបនេះផ្ទាល់ ។

ជាការកត់សំគាល់ អំពីនីតិវិធីនៃការជំនុំជម្រះក្តីនេះ គឺមានលក្ខណៈស្មុគស្មាញ និងហ្មត់ចត់ជាងនីតិវិធី នៃការជំនុំជម្រះក្តី នៅក្នុងតុលាការជាតិ ដោយហេតុថា លក្ខណៈនៃឧក្រិដ្ឋកម្មដែលបានកើតឡើងកាលពី៣០ឆ្នាំមុន (ក្នុងសម័យកាលខ្មែរក្រហម) នោះវាមានលក្ខណៈធំធេងនិងស្មុគស្មាញជាងខ្លាំងណាស់ ដូចនេះ ទើបការកាត់សេចក្តីត្រូវតែហ្មត់ចត់ និងត្រឹមត្រូវ ដើម្បីធានាឱ្យបាននូវយុត្តិធម៌សំរាប់ភាគីទាំងអស់រួមទាំងជនជាប់ចោទ និងជនរងគ្រោះផងដែរ ។ ជាក់ស្តែង គឺថា កាលពីអំឡុងខែមុននេះ ចៅក្រមនៃសាលាដំបូងបាន ចោទសួរជនជាប់ចោទ **ឌុច** អំពីព្រឹត្តិការណ៍ គោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា រចនាសម្ព័ន្ធគ្រប់គ្រង ជម្លោះប្រដាប់អាវុធរវាង ពួកខ្មែរក្រហម និងកងទ័ពវៀតណាម ព្រមទាំងការទទួលខុសត្រូវរបស់ជនជាប់ចោទរូបនេះនៅក្នុងមន្ទីរស-២១ ដែលគាត់មានតួនាទីជាអ្នកគ្រប់គ្រង ។ ដោយឡែក នៅក្នុងកំឡុងខែកក្កដា-សីហានេះវិញ ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ក៏បានកោះអញ្ជើញសាក្សីសំខាន់ៗបន្ថែមទៀត ឱ្យចូលមកបំភ្លឺ (ផ្តល់សក្ខីកម្ម) ដែលអ្នកទាំងនោះធ្លាប់ជាអតីតកម្មាភិបាល ភ្នាក់ងារសន្តិសុខ អ្នកសួរចំលើយ និងដែលធ្លាប់ស្ថិតនៅក្រោមបញ្ជារបស់ជនជាប់ចោទប្រធានមន្ទីរស-២១ ក៏ដូចជា សាក្សីជាអ្នកជំនាញប្រវត្តិសាស្ត្រផងដែរ ។

លោក **ម៉ម ណៃ** ហៅ **ចាន់** អាយុ ៧៦ឆ្នាំ ធ្លាប់ជាប្រធានក្រុមអ្នកសួរចំលើយនៅមន្ទីរស-២១ នៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានកោះហៅឱ្យចូលរួមបំភ្លឺផ្តល់សក្ខីកម្មជូនអង្គសវនាការមុនគេ ។ នៅពេលផ្តល់សក្ខីកម្មជូនអង្គសវនាការ សាក្សី **ម៉ម ណៃ** បានបង្កឱ្យមានការចាប់អារម្មណ៍ទៅដល់អ្នកចូលរួមសវនាការ ដោយសារគាត់ខ្លាចមិនហ៊ានឆ្លើយនូវសំណួរពីចៅក្រមដោយត្រង់ៗ ព្រោះថា គាត់ខ្លាច ការឆ្លើយនោះអាចដាក់បន្ទុកលើខ្លួនឯងចំពោះឧក្រិដ្ឋកម្ម ដែលគាត់ធ្លាប់បានចូលរួមនៅក្នុងមន្ទីរស-២១។ ផ្ទុយទៅវិញ លោក **ម៉ម ណៃ** បានជំរាបអង្គសវនាការថា គាត់មិនបានដឹងអំពីការធ្វើទារុណកម្ម និងកាប់សម្លាប់ហើយ ក៏មិនមានការសោកស្តាយចំពោះអំពើដែលកើតឡើងនៅក្នុងរបបនោះដែរ ។ ដោយសារការឆ្លើយមិនពិតនូវចំណុចមួយចំនួនរបស់សាក្សីរូបនេះ ទើបជនជាប់ចោទ **ឌុច** បាននិយាយថា *"សុំកុំខ្លាច ក្នុងការនិយាយការពិត ត្រូវតែនិយាយការពិត ។ ដោយសារតែខ្ញុំយល់ព្រម ឬទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលខ្ញុំបាន ប្រព្រឹត្ត ខ្ញុំចង់ឱ្យអ្នកធ្វើដូចខ្ញុំអញ្ចឹង ។"* នៅខណៈពេលនោះ លោកចៅក្រម **និល ណុល** បានសំរេចតែងតាំងឱ្យមានមេធាវី **គង់ សំអុន** ជួយសម្រួលដល់អារម្មណ៍ របស់សាក្សី **ម៉ម ណៃ** ដើម្បីចៀស វាងការឆ្លើយដាក់បន្ទុកខ្លួនឯងនៅ ពេលផ្តល់សក្ខីកម្មជូនអង្គសវនាការបែបនេះ ។

សាក្សីជាអតីតកម្មាភិបាលមន្ទីរស-២១ ម្នាក់ទៀត គឺលោក **ហ៊ឹម ហ៊ុយ** ដែលធ្លាប់ជាពេជ្ឈឃាតសម្លាប់អ្នកជាប់ឃុំនៅមន្ទីរស-២១ ដែរ។ នៅក្នុងសវនាការថ្ងៃទី១៦ ខែកក្កដាកន្លងទៅ លោក បានជំរាបប្រាប់អង្គចៅក្រមថា នៅក្នុងមន្ទីរស-២១ គាត់មានតួនាទីជា អ្នកការពារផ្នែកខាងក្រៅ ដឹកជញ្ជូន

អ្នកទោសយកទៅសម្លាប់នៅទី ពិឃាតជើងឯក ចាប់ចងអ្នកទោស និងសម្លាប់(កំទេច) អ្នកទោស ។

សាក្សី **ហ៊ឹម ហ៊ុយ** បាននិយាយបន្ថែមថា រាល់លិខិតបើកផ្លូវ ដើម្បីទៅយកអ្នកទោសនៅតាមខេត្តនានាមកដាក់ឃុំខ្លួននៅមន្ទីរ ស-២១ គឺធ្វើតាមបញ្ជារបស់ **ឌុច** ដែលជាប្រធាន ហើយលិខិតនេះត្រូវបានចេញដោយលោក **សុន សេន** (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកក្រសួងការពារជាតិ, បានស្លាប់ហើយ) ។ គាត់បាននិយាយថាគាត់ធ្លាប់ដឹកអ្នកទោសជនជាតិវៀតណាមចំនួនពីរដង និងមានគ្នា ពី១៥ ទៅ២០នាក់ និងដឹកអ្នកទោសពីខេត្តបាត់ដំបង និងខេត្តព្រះសីហនុផងដែរ ។ លោក **ហ៊ឹម ហ៊ុយ** ក៏បានបញ្ជាក់ប្រាប់សវនាការដែរថា ក្នុងឋានៈជាបុគ្គលិកម្នាក់នៅក្នុងមន្ទីរស-២១ គាត់ធ្លាប់បានទទួលការបង្រៀនពី **ឌុច** គឺថា *"គាត់បញ្ជាឱ្យសម្លាប់ មិនមែនគ្រាន់តែជាអ្នកទោសនៅមន្ទីរស-២១ ទេ តែអ្នកទោសផ្សេងៗទៀតនៅក្នុងប្រទេសកម្ពុជា"*។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ **ឌុច** បានបដិសេធច្រើនទៅលើសំដីបំភ្លឺរបស់សាក្សី ដែលធ្លាប់ជាអតីតអ្នកក្រោមឱវាទរូបរបស់គាត់រូបនេះ ។

មិនខុសពីសាក្សីពីររូបអតីតកម្មាភិបាលខ្មែរក្រហម ដែលបានផ្តល់សក្ខីកម្មរួចហើយ លោក **ប្រាក់ ខន** ក៏ជាសាក្សីទី៣ ត្រូវបានកោះហៅមកបំភ្លឺនៅចំពោះសាលាក្តីខ្មែរក្រហមផងដែរ ។ លោក **ប្រាក់ ខន** អតីតសន្តិសុខ និងអ្នកសួរចំលើយនៅក្នុងមន្ទីរស-២១ នៃរបបខ្មែរក្រហមបាននិយាយប្រាប់ចៅក្រមរបស់សាលាក្តីខ្មែរក្រហមថា លោកធ្លាប់ទទួលបន្ទុកជាអ្នកយាមនៅខាងក្រៅមន្ទីរឃុំឃាំង ហើយថាទីតាំងវិទ្យុសំបុកឃ្មុំបច្ចុប្បន្នគឺធ្លាប់ជាទីកន្លែងដែលលោកស្នាក់អាស្រ័យនៅពេលសំរាកពីធ្វើការ ។ នៅពេលជាបុគ្គលិកនៅមន្ទីរស-២១ នោះ លោកបានធ្វើការក្នុងក្រុមមួយ ដែលមានគ្នាប្រមាណ១០ ទៅ ១២ នាក់ ដែលមានភារកិច្ចយាមកាមនៅបរិវេណខាងក្រៅ គឺ ជួយបិទ-បើករបាំងផ្លូវ និងការពារមិនឱ្យមនុស្សចំលែកចូលនៅកន្លែងធ្វើការដែលជាកន្លែងសំខាន់ ។ សាក្សីរូបនេះបាននិយាយបន្តទៀតថា លោកបានឃើញអ្នកទោសត្រូវបានគេដឹកតាមរថយន្តមកដាក់នៅក្នុងមន្ទីរស-២១ និងមានអ្នកទោសខ្លះមិនឃើញដាក់ខ្នោះអ្វីនោះទេ ប៉ុន្តែក្រោយមកទើបគេដាក់ខ្នោះ ។នៅពេលដែលធ្វើការជាអ្នកសួរចំលើយពីដំបូងលោកមិន ចេះសួរទេ តែត្រូវបាន **ឌុច** បង្រៀនតិចតួចនូវវិធីសាស្ត្រសួរចំលើយ និងការធ្វើទារុណកម្ម ដើម្បីចំលើយសារភាពពីអ្នកទោសទាំងនោះ ។ ទាក់ទិននឹងការធ្វើទារុណកម្ម លោក **ប្រាក់ ខន** បានរៀបរាប់ថា មានវិធីសាស្ត្រក្នុងការសួរចំលើយមួយចំនួនដោយប្រើទារុណកម្ម ជាអាទិ៍ៈ ច្រកថង់ ចាកម្ជុលក្នុងក្រចក វាយនឹងរំពាត់ប្ញសឈាម ជាដើម ហើយ ពាក្យថា CIA និង KGB គឺ **ឌុច** ជាអ្នកបង្រៀន ។ លោកក៏បានបន្ថែមផងដែរថា លោកធ្លាប់បានឃើញឈ្លើយសឹកវៀតណាម ដែលត្រូវបានគេចាប់មកដាក់ឃុំខ្លួនទាំងស្រី ទាំងប្រុស ហើយថា កូនក្មេង អាយុ ៧-៨ ខែ ត្រូវបានគេទំលាក់ពីអគារមន្ទីរស-២១ ហើយខ្លួនលោកផ្ទាល់ជា អ្នកយកទៅកប់ចោល ។ ទោះបីជាយ៉ាងក៏ដោយ **ឌុច** តែងតែបដិសេធនូវសក្ខីកម្មខ្លះ ដោយជនជាប់ចោទរូបនេះ បានលើកឡើងថា សាក្សី **ប្រាក់ ខន** បាននិយាយមិនពិតប្រាប់ដល់អង្គសវនាការ ។

នៅខែសីហានេះដែរសាក្សីអ្នកជំនាញដែលជាប្រវត្តិវិទូរដ៏ល្បីឈ្មោះ និងជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យនៅប្រទេសអូស្ត្រាលី ឈ្មោះ **ដេវីត ឆេនល័រ** (David Chandler) ក៏បានផ្តល់សក្ខីកម្មជូនចៅក្រមអង្គជំនុំជម្រះសាលាដំបូងផងដែរ ។ លោក **ឆេនល័រ** បានជំរាបជូនចៅក្រមថា *មន្ទីរស-២១* មានតួនាទីសំខាន់ណាស់ ហើយខុសប្លែកមន្ទីរសន្តិសុខដទៃទៀត ដោយសារតែមន្ទីរស-២១ នេះ ប្រតិបត្តិការដោយសំងាត់បំផុត និង ជាទីកន្លែងដែលត្រូវសំលាប់អ្នកណា ដែលចាត់ទុកជាសត្រូវរបស់កម្ពុជាប្រជាធិបតេយ្យ ។ ចំពោះ *ចរិតលក្ខណៈ និង ភាពជាប់ពាក់ព័ន្ធរបស់ **ឌុច*** ក្នុងឋានៈជាប្រធានមន្ទីរស-២១ នេះ វិញ លោក **ឆេនល័រ** បាននិយាយថា បើទោះជាគាត់មិនបានសំភាសន៏ ដោយផ្ទាល់ជាមួយនឹង **ឌុច** នៅក្នុងការសិក្សារបស់គាត់អំពីមន្ទីរស-២១នេះក៏ដោយ ក៏គាត់ធ្លាប់បានប្រាស្រ័យជាមួយនឹងអតីតកម្មាភិបាល ក្រោមឱវាទ **ឌុច** ដែរ។ តាមការវិភាគរបស់លោក **ឆេនល័រ** គឺថា *"ឌុច មានសេចក្តីសប្បាយរីករាយចំពោះការងាររបស់ខ្លួន និងចង់ឱ្យ មន្ទីរស- ២១នេះ ត្រូវបានបក្ស និងសហគមន៏អន្តរជាតិ មើលឃើញថា វាជាអង្គការមួយ ដែលមានលក្ខណៈប្រកបដោយវិជ្ជាជីវៈ និងមានប្រសិទ្ធភាព ហើយវាក៏ជាមោទភាពរបស់គាត់ផ្ទាល់ខ្លួនផងដែរ ។"*

យោងតាមការប៉ាន់ប្រមាណកន្លងមក គឺប្រហែលជានៅខែតុលាខាងមុខនេះ ទើបសវនាការកាត់សេចក្តី **ឌុច** នឹងអាចបញ្ចប់ពេញលេញ ប្រសិនបើមិនមានបញ្ហាអ្វីកើតឡើងនោះទេ៕

## អាពាហ៍ពិពាហ៍ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) (ត)

## Marriages in the Khmer Rouge Regime (cont.)

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម មិនអនុញ្ញាតដាច់ខាតនូវការរួមភេទដោយមិនបានរៀបការ ។ ការរៀបការនៅក្នុងរបបខ្មែរក្រហមតែងតែប្រព្រឹត្តទៅជាច្រើនគូ ក្នុងពេលមួយលើកៗ ។ អ្នកដែលអាចរៀបការបាន គឺថាស្ត្រីអាយុយ៉ាងតិចភាគច្រើន ចាប់ពី២០ឆ្នាំ ហើយបុរសអាយុចាប់ពី២៥ឆ្នាំឡើងទៅ ។ ការរៀបការជាទូទៅត្រូវធ្វើ ឡើងដោយមិនបានដឹងខ្លួនមុន ឬ មានការស្ម័គ្រចិត្តទាំងសងខាងនោះទេ ។ ការបង្ខំឱ្យរៀបការបែបនេះ មិនសំដៅទៅលើតែអ្នកមាន វ័យក្មេងឬនៅលីវប៉ុណ្ណោះឡើយ គឺទាំងអ្នកមានវ័យចំណាស់ អ្នកដែលបាន

បែកគ្នានៅថ្ងៃរំដោះ ឬ បែកគ្នាដោយសារសង្គ្រាម អ្នកកំពុងជាប់ ពន្ធនាគារ ពោះម៉ាយ មេម៉ាយ រួមទាំងស្ត្រីមេម៉ាយដែលប្តីរបស់ខ្លួន ទើបតែគេយកទៅសម្លាប់ចោលផងដែរ ។

បើតាមការស្រាវជ្រាវរបស់អង្គការអន្តរជាតិមួយ ឈ្មោះថា UNIFEM បានរកឃើញថា មានស្ត្រីប្រមាណជា ២៥០,០០០ នាក់ ត្រូវបានរៀបការនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ *តើហេតុអ្វី បានជាខ្មែរក្រហមបង្ខំមនុស្សឱ្យរៀបការ?* ខ្មែរក្រហមដឹងថាខ្លួនបានកាប់សម្លាប់មនុស្សអស់ជាច្រើនក្នុងមួយថ្ងៃៗ រួមទាំងអ្នកស្លាប់ ដោយសារជំងឺ និងការអត់អាហារជាច្រើននាក់ទៀត។ ហេតុនេះ ខ្មែរក្រហមត្រូវរកមធ្យោបាយ ដើម្បីឱ្យមានមនុស្សបន្តវេនបុព្វហេតុបដិវត្តន៍របស់ខ្លួន។ លើសពីនេះទៀត ខ្មែរក្រហមយល់ថា មនុស្សដែលកើតមកថ្មីនេះជាមនុស្សដែលស្អាតស្អំមិនជាប់ជំពាក់ទាក់ទងឬមានសតិអារម្មណ៍ពីរបបមុនៗ ដែលពួកគេយល់ឃើញថា ជាសត្រូវរបស់ខ្លួន ហើយមនុស្សដែលកើតមកថ្មីនេះ ជាកូនរបស់អង្គការពិតប្រាកដ។ ការបង្ខំឱ្យរៀបការជាវិធានការចាំបាច់របបសរបបនេះដោយគេមិនគិតខ្វល់ពីមនោសញ្ចេតនា ដែលគូស្រករត្រូវរស់នៅជាមួយគ្នានោះទេ ដោយតម្រូវឱ្យពួកគេធ្វើការប្តេជ្ញាថា ត្រូវរស់នៅជាមួយគ្នា បន្ទាប់មក គូស្រករទាំងនោះត្រូវរួមភេទនឹងគ្នាដោយមានការតាមដានពីអង្គការទៀតផង ។

ទន្ទឹមនោះដែរក៏មានការបង្ខំឱ្យរៀបការជាមួយជនពិការ ដោយសង្គ្រាមបានកើតមានជាញឹកញាប់ អាចជាការលើកទឹកចិត្តដល់អ្នកតស៊ូបដិវត្តផងដែរ។ មានអ្នកខ្លះបានតស៊ូដើម្បីបដិវត្តន៍ ហើយត្រូវធ្លាក់ខ្លួនពិការដោយសារសង្គ្រាម។ តាមឯកសារស្រាជ្រាវរបស់អ្នកស្រី **ម៉ម កល្យាណី** មាននាងម្នាក់បាននិយាយនូវហេតុការណ៍នៃការរៀបការរបស់នាងថាៈ "*...ពេលខ្ញុំទើបត្រឡប់ពីស្ទូងវិញ..ខ្ញុំគ្រាន់តែបានដឹងថានៅថ្ងៃស្អែកត្រូវរៀបការ.... ។ ការរៀបការពេលនោះ មាន១៦០គូ ហើយពេលនោះម្នាក់ៗ ខិតខំពិនិត្យមើលគូរបស់ខ្លួន ក្រែងលោបាត់ផ្នែកណាមួយនៃរាងកាយ ។ ពេលនោះ មានស្ត្រីម្នាក់បានស្រែកយំឡើង ដោយបានឃើញគូរបស់ខ្លួនបាត់ដៃម្ខាង........ តែរូបនាងបានជួយលួងលោម .....ព្រោះគេអាចនឹងសម្លាប់ស្ត្រីនោះចោល ។*"

ខ្មែរក្រហមមិនគ្រាន់តែគិតគូររឿងអ្នកបន្តវេនបដិវត្តប៉ុណ្ណោះទេប៉ុន្តែទាំងការគ្រប់គ្រងការរួមភេទ និងកំលាំងពលកម្មសំរាប់ផលិតកសិផល ទៀតផង។ ក្រោយពេលរៀបការខ្មែរក្រហមបានកំណត់ឱ្យគូស្រករទាំងនោះ ត្រូវរស់នៅជាមួយគ្នាក្នុងរយៈពេលមួយ-ពីរ ថ្ងៃ ឬអាចរយៈពេលមួយអាទិត្យសំរាប់អ្នកមានឋានៈខ្លះតែប៉ុណ្ណោះ។ បន្ទាប់មក ពួកគេត្រូវត្រឡប់ទៅធ្វើការតាមអង្គភាពរៀងៗខ្លួនវិញ ដោយត្រូវរស់នៅដាច់ដោយឡែកពីគ្នា។ ការងារនៅរបបខ្មែរក្រហម គ្មានថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យទេ។ ខ្មែរក្រហមបានយកយប់ថ្ងៃទី ១០ ទី២០ ជាយប់សំរាប់អ្នកមានប្តីប្រពន្ធអាចនៅជាមួយគ្នាបាន។ ទោះជា ប្តី-ប្រពន្ធនឹងគ្នាក៏ដោយការជួបគ្នាមិនអាចជួបដោយឯកឯងបានឡើយ ត្រូវមានការសុំការអនុញ្ញាតពីអង្គការជាមុនបើមិនដូច្នោះទេពិតជាមានទោស។ ខ្មែរក្រហមបានដាក់ប្តី-ប្រពន្ធឱ្យនៅដាច់ពីគ្នាមិនត្រឹមតែ ពួកគេអាចងាយស្រួលក្នុងគ្រប់គ្រងការរួមភេទប៉ុណ្ណោះទេ ប៉ុន្តែងាយស្រួល ក្នុងការទាញយកកំលាំងពលកម្មពីពួកគេផងដែរ។

ទោះជាយាងណាក៏ដោយ គេមិនដែលឃើញមានការសុំ ឬការអនុញ្ញាតឱ្យលែងលះដល់គូស្រករ ដែលបានរៀបការកន្លង មកទេ ទោះគេមិនស្រឡាញ់គ្នា ឬមានបញ្ហាអ្វីក៏ដោយត្រូវតែខិតខំស៊ូទ្រាំរស់នៅជាមួយគ្នាទាំងសងខាងនិងលាក់បាំងការពិតទាំងនោះបើមិនដូច្នោះទេ នឹងត្រូវអង្គការកសាង ធ្វើទារុណកម្ម ឬសម្លាប់ចោល។

ជនរងគ្រោះអំពើហិង្សាផ្លូវភេទរវាងឆ្នាំ១៩៧៥-១៩៧៩
សូមទាក់ទងៈ អង្គការអ្នកច្បាប់ការពារសិទ្ធិកម្ពុជា
អាសយដ្ឋានៈ ផ្ទះ១២ ផ្លូវ២៨២ សង្កាត់បឹងកេងកង១
ខណ្ឌចំការមន
ទូរស័ព្ទៈ ០២៣ ៧៣០ ០៣២
០១២ ៩១៤ ៩៣២

## ព័ត៌មានសំខាន់ៈ

➢ ប្រសិនបើលោកអ្នកចាប់អារម្មណ៍ចង់ចូលរួមដាក់ពាក្យបណ្តឹង**ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី** និង**ជាសាក្សីនៅចំពោះមុខសាលាក្តីខ្មែរក្រហម**

**សូមទាក់ទងៈ**

- **សមាគមអាដហុក (ADHOC)**
  លេខទូរស័ព្ទៈ ០២៣ ៩៩០ ៥៤៤, ០២៣ ២១៨ ៦៥៣
- វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ **(KID)**
  លេខទូរស័ព្ទៈ ០២៣ ២១៤ ៩២៨
- មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម **(CSD)**
  លេខទូរស័ព្ទៈ ០២៣ ៣៦៤ ៧៣៥
- អង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស **(KKKHRA)**
  លេខទូរស័ព្ទៈ ០២៣ ៩៩៣ ៤៨៦
- អង្គភាពជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
  លេខទូរស័ព្ទៈ ០២៣ ២១៤ ២៩១

➢ ស្តាប់កម្មវិធីឃ្លាំមើលសាលាក្តីដែលមានផ្សាយបន្តផ្ទាល់ និងចាក់ផ្សាយឡើងវិញតាមវិទ្យុ FM ១០២ រៀងរាល់ ថ្ងៃពុធ ម៉ោង ៥:៣០ - ៦:៣០ ល្ងាច ។
➢ សូមស្រាវជ្រាវព័ត៌មានបន្ថែមលើគេហទំព័រ **www.krtrial.info**

*ទស្សនៈទាំងឡាយដែលមាននៅក្នុងអត្ថបទនៃសលាកប័ត្រព័ត៌មាននេះ មិនមែនឆ្លុះបញ្ចាំងពីទស្សនៈរបស់ អ៊ិន.អ៊ី.ឌី(**NED**) និង ឌី.អ៊ី.ឌី(**DED**) ទេ។*
**ឧបត្ថម្ភមូលនិធិដោយៈ អ៊ិន.អ៊ី.ឌី និង ឌី.អ៊ី.ឌី**
NED The National Endowment for Democracy
Supporting freedom around the world
ded Deutscher Entwicklungsdienst